PESTECH

# PESTECH

## ផេសថិក (ខេមបូឌា) ម.ក

## របាយការណ៍ត្រីមាស

សម្រាប់ត្រីមាសទីពីរនៃឆ្នាំហិរញ្ញវត្ថុដែលបានបញ្ចប់

នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២១

PESTECH

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| បរិយាយ | | ត្រីមាសទីពីរ ឆ្នាំ ២០២១ (លានរៀល) | ឆ្នាំ ២០២០ (លានរៀល) |
|---|---|---|---|
| **ស្ថានភាពហិរញ្ញវត្ថុ** | | | |
| ទ្រព្យសកម្មសរុប | | ១ ០៤៨ ៨៦៤ | ១ ០១៦ ១១២ |
| បំណុលសរុប | | ៩៦៨ ៩០៩ | ៩៤៦ ១៥៥ |
| មូលធនសរុប | | ៧៩ ៩៥៥ | ៦៩ ៩៥៧ |
| **លទ្ធផលហិរញ្ញវត្ថុ** | | **ត្រីមាសទីពីរ ឆ្នាំ ២០២១ (លានរៀល)** | **ត្រីមាសទីពីរ ឆ្នាំ ២០២០ (លានរៀល)** |
| ចំណូលសរុប | | ៣៥ ៩២៤ | ៤៤ ១៥៣ |
| (ខាត)/ចំណេញ មុនបង់ពន្ធ | | (១ ៦៥៧) | ៣១ ១៤៣ |
| (ខាត)/ចំណេញ ក្នុងការិយបរិច្ឆេទ | | (១ ៦៦៩) | ២៦ ២១៥ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | | (១ ០៥០) | ២៣ ០៣០ |
| **អនុបាតហិរញ្ញវត្ថុ** | | **ត្រីមាសទីពីរ ឆ្នាំ ២០២១ (លានរៀល)** | **ឆ្នាំ ២០២០ (លានរៀល)** |
| អនុបាតសាធនភាព | | (០,២០%) | ៧,៤៣% |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត | ០,៨៣ | ០,២៨ |
| | អនុបាតចរន្តលឿន | ០,៨១ | ០,២៤ |
| | | **ត្រីមាសទីពីរ ឆ្នាំ ២០២១ (លានរៀល)** | **ត្រីមាសទីពីរ ឆ្នាំ ២០២០ (លានរៀល)** |
| អនុបាតចំណេញភាព | អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម | (០,១៦%) | ២,៧៩% |
| | អនុបាតចំណេញធៀបនឹងមូលធន | (២,០៩%) | ៣២,៥៩% |
| | អនុបាតគម្លាត(ខាត)/ចំណេញដុល | ២៥,១៨% | ១០២,៩៤% |
| | អនុបាតគម្លាត(ខាត)/ចំណេញភាព | (៤,៦៥%) | ៥៩,៣៧% |
| | (ខាត)/ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | (២២,៤៩) | ៣៦៩,២៣ |
| អនុបាទលទ្ធភាពបង់ការប្រាក់ | | ០,៧៥ | ៤,៩១ |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (ប្រសិនមាន) | | - | - |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត (ប្រសិនមាន) | | - | - |

PESTECH

# សមាសភាពក្រុមប្រឹក្សាភិបាល



Paul Lim Pay Chuan

ប្រធានក្រុមប្រឹក្សាភិបាល



Lim Ah Hock

អភិបាល



Han Fatt Juan

នាយកប្រតិបត្តិ/ប្រធាននាយកប្រតិបត្តិ



Charles Tan Pu Hooi

អភិបាល



ដាវ អានសាន

អភិបាលឯករាជ្យ

PESTECH

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

ភាគហ៊ុនិក ជាទីរាប់អាន!

ខ្ញុំមានសេចក្តីសោមនស្សរីករាយជាខ្លាំងក្នុងការបង្ហាញទៅកាន់អ្នកទាំងអស់គ្នា នូវរបាយការណ៍ប្រចាំត្រីមាសទីពីរប្រចាំឆ្នាំ ២០២១ របស់ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក ("PCL")។

នៅក្នុងអំឡុងត្រីមាសក្រោមការត្រួតពិនិត្យឡើងវិញ ពោលគឺក្នុងរយៈពេលចាប់ពី ខែតុលា រហូតដល់ ខែធ្នូ ឆ្នាំ ២០២០ PCL នៅតែបន្តដំណើរការក្រោមឥទ្ធិពលផលប៉ះពាល់នៃជំងឺរាតត្បាតសកល ដែលជះឥទ្ធិពលទូទៅដល់ការធ្វើដំណើរជាអន្តរជាតិ និងសកម្មភាពដឹកជញ្ជូន។ ការអនុវត្តការងាររបស់យើងនៅតែទទួលរងនូវការប៉ះពាល់ខ្លះៗ នៅពេលណាដែលមានតម្រូវការផ្នែកបច្ចេកទេសពីក្រុមជំនាញនៃអ្នកផ្គត់ផ្គង់ឧបករណ៍ធំៗអន្តរជាតិ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមបុគ្គលិកក្នុងស្រុករបស់ PCL ដែលជាបុគ្គលិកមានសមត្ថភាពដែលអាចបំពេញរាល់ភារកិច្ចចាំបាច់ទាំងអស់ដែលមាននៅក្នុងដៃក្នុងពេលដ៏លំបាកនេះ នៅខណៈពេលដែលឧស្សាហកម្មផ្សេងៗនៅលើពិភពលោកកំពុងពុះពារក្នុងការដំណើរការ។ ចំពោះរឿងនេះ យើងមានសំណាងដែលប្រតិបត្តិការរបស់យើងនៅកម្ពុជា មិនបានរងផលប៉ះពាល់គួរឱ្យកត់សម្គាល់ ដោយជំងឺរាតត្បាតសកលឡើយ ហើយ PCL នៅតែមានភាពអត់ធ្មត់ក្នុងការបន្តប្រតិបត្តិការអាជីវកម្មរបស់ខ្លួនក្រោមស្ថានភាពធម្មតាជាថ្មី ដែលបណ្តាលមកពីកូវីដ១៩ ។

PCL បានបន្តរុករកឱកាសនៅក្នុងផ្នែកថាមពលកកើតឡើងវិញនៅក្នុងប្រទេសកម្ពុជា និងក្នុងតំបន់ឥណ្ឌូចិន ដូចដែលយើងបានធ្វើរោងចក្រថាមពលបន្ទះសូឡាខ្នាតធំដំបូងរបស់យើង សង់ឡើងនៅក្រុងបាវិត ខេត្តស្វាយរៀង ។ ក្រុមហ៊ុនក៏បានកំពុងបន្តសកម្មភាពយ៉ាងសកម្ម នូវទស្សនវិស័យសម្រាប់គម្រោងបន្ទះថាមពលលើដំបូលខ្នាតឧស្សាហកម្ម ក្នុងគោលបំណងជួយដល់អ្នកប្រើប្រាស់ថាមពលធំៗ ក្នុងការធ្វើពិពិធកម្មប្រភពអគ្គិសនី ដោយរាប់បញ្ចូលទាំងជម្រើសថាមពលបៃតង ។

ផ្នែកហេដ្ឋារចនាសម្ព័ន្ធអនុស្ថានីយ៍ និង បណ្តាញបញ្ជូន នៅតែជាចំណូលប្រចាំរបស់យើង ហើយត្រូវបានគេរំពឹងទុកថា នឹងបន្តចូលរួមចំណែកយ៉ាងច្រើនដល់ការរីកចម្រើនរបស់ក្រុមហ៊ុន។ យើងបន្តប្តេជ្ញាចិត្តយ៉ាងមោះមុត ផ្តោះទៅរកការចូលរួមយ៉ាងសកម្មនៅក្នុងការស្ថាបនាផ្នែកហេដ្ឋារចនាសម្ព័ន្ធ បណ្តាញថាមពល នៅក្នុងប្រទេសកម្ពុជា ទន្ទឹមនឹងការពង្រីកវិសាលភាពរបស់យើងនៅក្នុងជំនួញថាមពលកកើតឡើងវិញ។

ក្រុមហ៊ុនបានរក្សានូវទស្សនៈវិស័យដ៏វែងឆ្ងាយរបស់ខ្លួននូវការរីកដុះដាលនៃកំណើនវិជ្ជមាននៅក្នុងតំបន់ជាពិសេសនៅក្នុងប្រទេសកម្ពុជា ហើយបានបន្តសាងសមត្ថភាពវិស្វកម្ម និង ស្វែងរកមធ្យោបាយផ្សេងៗដើម្បីបន្ថែមសេវាកម្មទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធថាមពលអគ្គីសនី ដែលបង្កើតឡើងសម្រាប់ប្រជាជាតិ និងប្រជាជននៅឥណ្ឌូចិន។

សូមអរគុណ!

Lim Pay Chuan

ប្រធានក្រុមប្រឹក្សាភិបាល

កាលបរិច្ឆេទៈ ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០២១

PESTECH

# សេចក្តីថ្លែងរបស់នាយកប្រតិបត្តិ

ភាគហ៊ុនិក ជាទីរាប់អាន!

ផេសថិក (ខេមបូឌា) ម.ក ("PCL") រកបានប្រាក់ចំណូលច្រើនសម្រាប់រយៈពេលប្រាំមួយខែនៃឆ្នាំហិរញ្ញវត្ថុ ២០២១ ក្រុមហ៊ុនក៏បានបន្តផ្តោតការយកចិត្តទុកដាក់លើការប្រតិបត្តិនៃគម្រោង ដែលមាននៅក្នុងដៃក្នុងកំឡុងពេលដ៏លំបាកនេះ ក្រោមឥទ្ធិពលនៃជំងឺរាតត្បាត ដែលបណ្តាលមកពីកូវីដ១៩។

ទោះជាយ៉ាងណាក៏ដោយ ដោយសារតែដំណាក់កាលនៃការអនុវត្តគម្រោង ធ្វើអោយក្រុមហ៊ុនយើងមានថ្លៃដើមប្រតិបត្តិការច្រើនជាងមុនដូចអំឡុងពេលត្រីមាសដូចគ្នា ដែលជះឥទ្ធិពលដល់ប្រាក់ចំណេញប្រតិបត្តិការសម្រាប់រយៈពេលជាក់លាក់នេះ ។

ការអនុវត្តការងារដែលទាក់ទងជាមួយគម្រោងអនុស្ថានីយ៍រ៉ែមាសនៅតំបន់អូរខ្វារ នៅខេត្តមណ្ឌលគីរី ព្រមជាមួយគ្នានឹងគម្រោងបណ្តាញបញ្ជូនប្រវែង ១៣៥ គីឡូម៉ែត្រ រវាងខេត្តឧត្តរមានជ័យ និង អនុស្ថានីយ៍បណ្តាញសៀមរាបភាគខាងកើត ដែលគម្រោងទាំងពីរនេះត្រូវបានអនុវត្តយ៉ាងសកម្មនៅក្នុងត្រីមាសនេះ។

យើងនៅតែបន្តប្រុងប្រយ័ត្នខ្ពស់ក្នុងអំឡុងពេលនៃស្ថានភាពមិនជាក់លាក់នៃជំងឺរាតត្បាតសកលនេះ ប៉ុន្តែយើងនៅតែបន្តប្តេជ្ញាចិត្តយ៉ាងពេញលេញ ក្នុងការអនុវត្តគម្រោងដែលមាននៅក្នុងដៃ ដើម្បីផ្តល់ជូនសេវាកម្មល្អបំផុតរបស់យើងដល់អតិថិជន និង អ្នកប្រើប្រាស់។

សូមអរគុណ!

Han Fatt Juan

ប្រធាននាយកប្រតិបត្តិ

កាលបរិច្ឆេទ៖ ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០២១

PESTECH

# មាតិកា

ព័ត៌មានហិរញ្ញវត្ថុសង្ខេប ..... i
ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ..... ii
សមាសភាពក្រុមប្រឹក្សាភិបាល ..... iii
សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ..... iv
សេចក្តីថ្លែងរបស់នាយកប្រតិបត្តិ ..... v

**ផ្នែកទី ១-ព័ត៌មានទូទៅពាក់ព័ន្ធនឹងក្រុមហ៊ុន**

ក. អត្តសញ្ញាណរបស់ក្រុមហ៊ុន

ខ. ប្រភេទអាជីវកម្ម

គ. ព្រឹត្តិការណ៍សំខាន់ប្រចាំត្រីមាស

**ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច**

ក. លទ្ធផលប្រតិបត្តិការធុរកិច្ច

ខ. រចនាសម្ព័ន្ធចំណូល

**ផ្នែកទី ៣ - របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យ**

**ផ្នែកទី ៤ - កិច្ចពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង**

ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

ខ. កត្តាសំខាន់ៗដែលជះឥទ្ធិពលលើផលចំណេញ

គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងប្រាក់ចំណូល

ឃ.ផលប៉ះពាល់នៃអត្រាប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងតម្លៃទំនិញ

ង. ផលប៉ះពាល់នៃអតិផរណា

ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងសាច់ប្រាក់របស់រាជរដ្ឋាភិបាល

**ផ្នែកទី ៥ - ព័ត៌មានដែលចាំបាច់ផ្សេងទៀតសម្រាប់ការការពារវិនិយោគិន (ប្រសិនបើមាន**

**ហត្ថលេខារបស់អភិបាលក្រុមហ៊ុន)**

PESTECH

## ផ្នែកទី ១ - ព័ត៌មានទូទៅពាក់ព័ន្ធនឹងក្រុមហ៊ុន

### ក. អត្តសញ្ញាណរបស់ក្រុមហ៊ុន

ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ៖ **ផេសថិក (ខេមបូឌា)ម.ក**

ជាអក្សរឡាតាំង៖ **PESTECH (Cambodia) PLC**

លេខកូដស្តង់ដា៖ **PEPC**

អាសយដ្ឋាន៖ **ផ្ទះលេខ ៦ ផ្លូវលេខ ៥៨៨ សង្កាត់បឹងកក់ទី II ខណ្ឌទួលគោក ភ្នំពេញ ប្រទេសកម្ពុជា**

លេខទូរសព្ទ៖ **+៨៥៥ ២៣ ៨៨២ ១០៥** ទូរសារ៖ **+៨៥៥ ២៣ ៨៨២ ១០៦**

គេហទំព័រ៖ www.pestech.com.kh អ៊ីមែល៖ **info@pestech.com.my**

លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម៖ **00000៩៥៧** កាលបរិច្ឆេទ៖ **ថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ ២០១០**

លេខអាជ្ញាប័ណ្ណអាជីវកម្ម៖ **៣២៦ Brk.DnS/ASN** ចេញដោយ៖ **MLMUPC**

កាលបរិច្ឆេទ៖ **ថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០១៨**

សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ៖ **១៧១/២០ គ.ម.ក / ស.ស.រ.**

គ.ម.ក កាលបរិច្ឆេទ៖ **២២ ខែកក្កដា ឆ្នាំ២០២០**

អ្នកតំណាងរបស់ក្រុមហ៊ុន៖ **Paul Lim Pay Chuan**

### ខ. ប្រភេទអាជីវកម្ម

PCL ចូលរួមជាចម្បងនៅក្នុងការផ្តល់ដំណោះស្រាយផ្នែកវិស្វកម្ម និងបច្ចេកទេសនៃប្រព័ន្ធអគ្គិសនីគ្រប់ជ្រុងជ្រោយសម្រាប់៖

- ការរចនាប្លង់ ការធ្វើលទ្ធកម្ម ការសាងសង់ ការដំឡើង និងការដាក់ឲ្យប្រើប្រាស់អនុស្ថានីយ៍ HV និង EHV ខ្សែបញ្ជូនអគ្គិសនី HV និង EHV ព្រមទាំងប្រព័ន្ធខ្សែកាបអគ្គិសនីក្រោមដី សម្រាប់បញ្ជូន និងចែកចាយអគ្គិសនីផងដែរ
- ការដំណើរការ និងថែទាំ ("O&M") ខ្សែបញ្ជូនអគ្គិសនី និងអនុស្ថានីយ៍ និង
- ការធ្វើជំនួញសមាសធាតុ និងបរិក្ខារប្រព័ន្ធអគ្គិសនីដែលមានពាណិជ្ជសញ្ញាជារបស់ខ្លួនឯង និងមិនមែនជារបស់ខ្លួនឯង។

### គ.ព្រឹត្តិការណ៍សំខាន់ប្រចាំត្រីមាស

នៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០២០ PCLបានបញ្ចប់ការបោះផ្សាយមូលបត្រលើកដំបូង និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រគោលនៃគណៈកម្មការមូលត្រកម្ពុជា

PESTECH

## ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលនៃដំណើរការធុរកិច្ច

### ក. លទ្ធផលនៃដំណើរការធុរកិច្ច

ដំណើរការនៃវិស្វកម្ម លទ្ធកម្ម ការសាងសង់ និង ការដាក់អោយដំណើរការ ("EPCC") កិច្ចសន្យា សំរាប់បណ្តាញអគ្គិសនី និងអនុស្ថានីយគឺជាកត្តាចូលរួមសំខាន់ចំពោះប្រាក់ចំណូលប្រចាំត្រីមាស ដែលមានតម្លៃទឹកប្រាក់ចំនួន ៣២ ៧២៤ លានរៀល (ត្រីមាសទីពីរនៃឆ្នាំហិរញ្ញវត្ថុ ២០២០៖ ៤២ ៣៣៤ លានរៀល) ដែលស្មើនឹងប្រមាណ ៩១,១% (ត្រីមាសទីពីរនៃឆ្នាំហិរញ្ញវត្ថុ ២០២០៖៩៥,៩%) ធៀបនឹងប្រាក់ចំណូលសរុប។

ការបំពេញបន្ថែមនៃសេវាកម្ម EPCC របស់យើងដែលជាប្រតិបត្តិការនិងថែទាំ ដែលស្មើនឹងប្រមាណ ៣ ២០០ លានរៀល ឬ ៨,៩% នៃប្រាក់ចំណូលសរុប (ត្រីមាសទីពីរនៃឆ្នាំហិរញ្ញវត្ថុ ២០២០៖ ១ ៨១៩ លានរៀល ឬ៤,១%) ។ ការកើនឡើងប្រាក់ចំណូល ត្រូវបានទទួលស្គាល់ក្រោមប្រតិបត្តិការនិងថែទាំ បើប្រៀបធៀបទៅនឹងត្រីមាសដូចគ្នានៃឆ្នាំហិរញ្ញវត្ថុមុន ដែលភាគច្រើនគឺបណ្តាលមកពីការបញ្ចប់ប្រតិបត្តិការនៃគម្រោងនៅក្រុងព្រះសីហនុ នៅខែ មីនា ឆ្នាំ ២០២០ ។

### ខ. រចនាសម្ព័ន្ធចំណូល

| ល.រ. | ប្រភពចំណូល | ត្រីមាសទីពីរ ឆ្នាំ ២០២១ | | ត្រីមាសទីពីរ ឆ្នាំ ២០២០ | | បម្រែបម្រួល | |
|---|---|---|---|---|---|---|---|
| | | លានរៀល | ភាគរយ | លានរៀល | ភាគរយ | លានរៀល | ភាគរយ |
| ១ | វិស្វកម្ម លទ្ធកម្ម ការសាងសង់ និង ការដាក់អោយដំណើរការ ("EPCC") កិច្ចសន្យា សំរាប់បណ្តាញអគ្គិសនី និងអនុស្ថានីយ | ៣២ ៧២៤ | ៩១,១ | ៤២ ៣៣៤ | ៩៥,៩ | (៩ ៦១០) | (២២,៧) |
| ២ | ប្រតិបត្តិការនិងថែទាំ | ៣ ២០០ | ៨,៩ | ១ ៨១៩ | ៤,១ | ១ ៣៨១ | ៧៥,៩ |
| | ប្រាក់ចំណូលសរុប | ៣៥ ៩២៤ | ១០០ | ៤៤ ១៥៣ | ១០០ | (៨ ២២៩) | (១៨,៦) |

PESTECH

## ផ្នែកទី ៣ - របាយការណ៍ហិរញ្ញវត្ថុដែលត្រូវធ្វើសវនកម្មដោយសវនករឯករាជ្យ

សូមយោងទៅតាមរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយត្រូវបានធ្វើការត្រួតពិនិត្យឡើងវិញរួចរាល់ហើយដោយសវនករឯករាជ្យ។

## ផ្នែកទី ៤ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ("MD&A")

### ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

១. ការវិភាគចំណូល

ចំណូលសរុបសម្រាប់បីខែនៃរយៈពេលហិរញ្ញវត្ថុដែលបានបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២០ បានកត់ត្រាត្រឹម ៣៥ ៩២៤ លានរៀល ថយចុះចំនួន ៨ ២២៩ លានរៀល ឬ ១៨,៦% បើប្រៀបធៀបទៅនឹងរយៈពេលត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន។

សម្រាប់រយៈពេលហិរញ្ញវត្ថុប្រាំមួយខែ ក្រោមការត្រួតពិនិត្យឡើងវិញ ប្រាក់ចំណូលត្រូវបានកត់ត្រាចំនួន ១១០ ១៥៨ លានរៀល កើនឡើង ២៣ ៧៨២ លានរៀល ឬ ២៧,៥% បើប្រៀបធៀបទៅនឹងប្រាក់ចំណូល ៨៦ ៣៧៦ លានរៀលសម្រាប់រយៈពេលនៃឆ្នាំហិរញ្ញវត្ថុមុន ។

បម្រែបម្រួលនៃប្រាក់ចំណូលសម្រាប់ត្រីមាសនៃឆ្នាំហិរញ្ញវត្ថុ២០២១នេះ ភាគច្រើនបណ្តាលមកពីដំណាក់កាលនៃការអនុវត្តគម្រោងដែលមានស្រាប់។

២. ការវិភាគចំណូលតាមផ្នែក

ដំណើរការនៃវិស្វកម្ម លទ្ធកម្ម ការសាងសង់ និង ការដាក់អោយដំណើរការ ("EPCC") កិច្ចសន្យាសម្រាប់បណ្តាញអគ្គិសនី និងអនុស្ថានីយគឺជាកត្តាចូលរួមសំខាន់ចំពោះប្រាក់ចំណូលប្រចាំត្រីមាសដែលមានតម្លៃទឹកប្រាក់ចំនួន ៣២ ៧២៤ លានរៀល (ត្រីមាសទីពីរនៃឆ្នាំហិរញ្ញវត្ថុ ២០២០៖ ៤២ ៣៣៤ លានរៀល) ដែលស្មើនឹងប្រមាណ ៩១,១% (ត្រីមាសទីពីរនៃឆ្នាំហិរញ្ញវត្ថុ ២០២០៖៩៥,៩%) ធៀបនឹងប្រាក់ចំណូលសរុប។

ការបំពេញបន្ថែមនៃសេវាកម្ម EPCC របស់យើង ដែលជាប្រតិបត្តិការនិងថែទាំដែលស្មើនឹងប្រមាណ ៣ ២០០ លានរៀល ឬ ៨,៩% នៃប្រាក់ចំណូលសរុប (ត្រីមាសទីពីរនៃឆ្នាំហិរញ្ញវត្ថុ ២០២០៖ ១ ៨១៩ លានរៀល ឬ ៤,១%)។ ការកើនឡើងប្រាក់ចំណូល ត្រូវបានទទួលស្គាល់ក្រោមប្រតិបត្តិការនិងសេវាថែទាំ បើប្រៀបធៀបទៅនឹងត្រីមាសដូចគ្នានៃឆ្នាំហិរញ្ញវត្ថុមុន ដែលភាគច្រើនគឺបណ្តាលមកពីការបញ្ចប់ប្រតិបត្តិការនៃគម្រោងនៅក្រុងព្រះសីហនុ នៅខែ មីនា ឆ្នាំ ២០២០ ។

៣. ការវិភាគគម្លាតចំណេញដុល

ចំណេញដុលនៅក្នុងត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ ត្រូវបានកត់ត្រាត្រឹម ២៥,១៨% បើប្រៀបធៀបទៅនឹងត្រីមាសមុននៃឆ្នាំហិរញ្ញវត្ថុមុន ដែលមានចំនួន ១០២,៩៤% ដោយថយចុះចំនួន ៧៧,៧៦%។ ការកើនឡើងចំណេញដុល ក្នុងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន គឺភាគច្រើនបណ្តាលមកពីការបញ្ចប់គម្រោងធំ។ ចំណេញដុលនៃវឌ្ឍនភាពគម្រោងក្នុងត្រីមាសបច្ចុប្បន្នគឺស្ថិតនៅក្នុងការរំពឹងទុករបស់យើង។

PESTECH

៤. ការវិភាគចំណេញ/(ខាត)មុនបង់ពន្ធ

ចំណេញ/(ខាត)មុនបង់ពន្ធ នៅក្នុងត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ ត្រូវបានកត់ត្រាត្រឹម ១ ៦៥៧ លានរៀល ដោយបានប្រៀបធៀបទៅនឹងចំណេញដុលមុនបង់ពន្ធ ដែលមានចំនួន ៣១ ១៤៣ លានរៀលនៃឆ្នាំហិរញ្ញវត្ថុមុន ដោយថយចុះចំនួន ៣២ ៨០០ លានរៀល ឬ ១០៥% ។

ចំណេញ/(ខាត)មុនបង់ពន្ធ នៅក្នុងត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ ត្រូវបានកត់ត្រាត្រឹម ១ ៨៥៥ លានរៀល ដោយបានប្រៀបធៀបទៅនឹងចំណេញដុលមុនបង់ពន្ធ ដែលមានចំនួន ៣២ ៨៦៥ លានរៀលនៃឆ្នាំហិរញ្ញវត្ថុមុន ដោយថយចុះចំនួន ៣៤ ៧២០ លានរៀល ឬ ១០៦% ។

ចំណេញ/(ខាត)មុនបង់ពន្ធ នៅក្នុងកំឡុងពេលបច្ចុប្បន្ន ភាគច្រើនបណ្តាលមកពីការចំណាយហិរញ្ញប្បទានរបស់សម្ព័ន្ធ មានចំនួន ១៤ ០៥០ លានរៀល បើប្រៀបធៀបទៅនឹងចំណាយហិរញ្ញប្បទានមានចំនួន ១២ ៨៤៤ លានរៀលដែលត្រូវបានកត់ត្រាក្នុងត្រីមាសឆ្នាំហិរញ្ញវត្ថុមុន គឺបណ្តាលមកពីតម្រូវការហិរញ្ញវត្ថុដែលបានមកពីកម្ចីធនាគារ សម្រាប់គម្រោងសាងសង់-ផ្ទេរ(Build- Transfer)។

៥. ការវិភាគចំណេញ/(ខាត)ក្នុងការិយបរិច្ឆេទ

លទ្ធផលបានបង្ហាញពីការខាតក្រោយពេលបង់ពន្ធសម្រាប់ត្រីមាសបច្ចុប្បន្នមានចំនួន១ ៦៦៩ លានរៀល និង ត្រីមាសទីមួយរួមបញ្ចូលជាមួយត្រីមាសទីពីរនៃឆ្នាំហិរញ្ញវត្ថុនេះ មានចំនួន ២ ៩៦៨ លានរៀល ។ សម្ព័ន្ធបានកត់ត្រាប្រាក់ចំណេញចំនួន១២ ០៨៥ លានរៀល ក្នុងសកម្មភាពប្រតិបត្តិការរយៈពេលប្រាំមួយខែចុងក្រោយនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ថ្លៃដើមហិរញ្ញប្បទានកើតចេញពីសកម្មភាពវិនិយោគ គួបផ្សំនឹងសំវិធានធនចំណាយលើពន្ធនៃ ពន្ធអប្បបរមា ១% នៃច្បាប់ស្តីពីសារពើពន្ធកម្ពុជា ដែលជាហេតុបណ្តាល ឱ្យមានការខាតក្នុងការិយបរិច្ឆេទនេះ ។

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

អំឡុងពេលក្រោមការត្រួតពិនិត្យឡើងវិញនេះ មិនមានកត្តាសំខាន់ៗណាមួយ ដែលជះឥទ្ធិពលលើប្រាក់ចំណេញរបស់សម្ព័ន្ធ ។

## គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ចំណូលសរុបសម្រាប់រយៈពេលបីខែនៃឆ្នាំហិរញ្ញវត្ថុ ដែលបានបញ្ចប់នៅថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ២០២០ ត្រូវបានកត់ត្រាត្រឹម ៣៥ ៩២៤ លានរៀល ដែលតំណាងឲ្យការថយចុះចំនួន ៨ ២២៩ លានរៀល ឬ ១៨,៦% ដោយប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន មានចំនួន ៤៤ ១៥៣ លានរៀល ។ សម្រាប់រយៈពេលប្រាំមួយខែហិរញ្ញវត្ថុក្រោមការត្រួតពិនិត្យឡើងវិញ ចំណូលត្រូវបានកត់ត្រាមានចំនួន ១១០ ១៥៨ លានរៀល ដែលតំណាងឱ្យការកើនឡើង ២៣ ៧៨២ លានរៀលឬ ២៧,៥% បើប្រៀបធៀបទៅនឹង ៨៦ ៣៧៦ លានរៀល សម្រាប់រយៈពេលនៃឆ្នាំហិរញ្ញវត្ថុមុន ។ បម្រែបម្រួលនៃប្រាក់ចំណូលសម្រាប់ត្រីមាសនៃឆ្នាំហិរញ្ញវត្ថុ២០២១នេះ ភាគច្រើន ជាចម្បងបណ្តាលមកពីដំណាក់កាលនៃការអនុវត្តគម្រោងដែលមានស្រាប់។

### ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ពុំមានផលប៉ះពាល់ធ្ងន់ធ្ងរ ដែលបណ្តាលមកពីអត្រាប្តូររូបិយប័ណ្ណបរទេស អត្រាការប្រាក់ និង ការឡើងចុះនៃតម្លៃទំនិញនោះទេ។

### ង. ផលប៉ះពាល់នៃអតិផរណា

ការចំណាយសម្រាប់អាជីវកម្មរបស់យើង គឺដោយសារផលប៉ះពាល់នៃអតិផរណា ដែលមានចំនួនប្រហែល ១៥% នៃ ចំណូលរបស់យើង។ ទោះបីជាយ៉ាងណាក៏ដោយ អតិផរណានៅក្នុងប្រទេសកម្ពុជាមានចំនួន ៣,៧% (គិតត្រឹមខែវិច្ឆិកា ឆ្នាំ ២០២០ ប្រភព: NBC: សន្ទស្សន៍តម្លៃអ្នកប្រើប្រាស់ និង អត្រាអតិផរណា) ដែលបានបង្កផលប៉ះពាល់ប្រហែល 0,៥៦% តែប៉ុណ្ណោះ ចំពោះប្រាក់ចំណេញរបស់យើង។ រាល់ចំណាយប្រតិបត្តិការទាំងអស់ មានតម្លៃថេរ នៅក្នុងរយៈពេលនៃកិច្ចសន្យាទាំងមូល។ ក្រៅពីការលើកឡើងខាងលើ ពុំមានផលប៉ះពាល់សំខាន់ៗផ្សេងទៀត ដែលបណ្តាលមកពីអតិផរណានោះទេ។

### ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

ពុំមានបម្រែបម្រួលសំខាន់ៗនៅក្នុងគោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ សាច់ប្រាក់របស់រាជរដ្ឋាភិបាល ឬកត្តានានាដែលមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះលទ្ធផលហិរញ្ញវត្ថុ នៅក្នុងអំឡុងឆ្នាំនេះទេ។

## ផ្នែកទី ៥ - ព័ត៌មានដែលចាំបាច់ផ្សេងទៀតសម្រាប់ការការពារវិនិយោគិន

ពុំមានព័ត៌មានដែលចាំបាច់ផ្សេងទៀតសម្រាប់ការការពារវិនិយោគិន។

PESTECH

**ហត្ថលេខារបស់អភិបាលក្រុមហ៊ុន**

(នឹងត្រូវបានចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល រឺយ៉ាងតិចដោយប្រធានប្រតិបត្តិចំនួនពីររូប)

បានអាន និងឯកភាពៈ

ហត្ថលេខា

ឈ្មោះ៖ Paul Lim Pay Chuan

មុខតំណែងៈ **ប្រធានក្រុមប្រឹក្សាភិបាល**